**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

**លេខៈ** 08/15 **សណ.គក**

ភ្នំពេញ ថ្ងៃទី 25 ខែ ឧសភា ឆ្នាំ២០១៥

# សេចក្តីណែនាំ
# ស្តី ពី
# តួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង
# និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន

**យោង:** -លក្ខន្តិកៈគណបក្សប្រជាជនកម្ពុជា
-សំណូមពរ នៃភារកិច្ចនយោបាយរបស់គណបក្ស នាដំណាក់កាលបច្ចុប្បន្ន
-ស្មារតីនៃអង្គប្រជុំគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៥
-មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល** ណែនាំអំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដូចខាងក្រោមៈ

## I.**តួនាទី ភារកិច្ច សិទ្ធិ**

### ក-អំពីតួនាទី

គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវបានបង្កើតនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ លើកលែងតែក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ។

គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន គឺជាអង្គការដឹកនាំរបស់គណបក្សក្នុងចន្លោះពីមហាសន្និបាតមួយទៅមហាសន្និបាតមួយទៀតនៃគណបក្សក្រសួង ស្ថាប័ន ។ គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ស្ថិតក្រោមការដឹកនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងមានការទទួលខុសត្រូវចំពោះមុខគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងគណបក្សថ្នាក់ខ្លួន ក្នុងការដឹកនាំ ត្រួតពិនិត្យការអនុវត្តគ្រប់វិស័យការងាររបស់គណបក្ស ដើម្បីសម្រេចភារកិច្ចនយោបាយដែលគណបក្សថ្នាក់លើបានកំណត់ និងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតគណបក្សថ្នាក់ខ្លួន។

ខ-អំពីភារកិច្ច

ភារកិច្ចសំខាន់ៗរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រួមមាន:

១-ផ្អែកលើលក្ខន្តិកៈ កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចនានារបស់គណៈកម្មាធិការកណ្តាល ច្បាប់បញ្ញត្តិជាធរមានរបស់រដ្ឋ និងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតគណបក្សថ្នាក់ខ្លួន ដើម្បីកំណត់ទិសដៅ ភារកិច្ច គោលការណ៍ និងវិធានការចាត់តាំងអនុវត្ត ឲ្យបានសមស្របតាមសភាពការណ៍ជាក់ស្តែងរបស់ក្រសួង ស្ថាប័ន ព្រមទាំងដឹកនាំអង្គការមូលដ្ឋានរបស់គណបក្សអនុវត្តឲ្យបានជោគជ័យ។

២-បំផុសលើកទឹកចិត្តដល់សមាជិកគណបក្ស និងមន្ត្រី បុគ្គលិក កម្មករ ឲ្យខិតខំប្រឹងប្រែងសម្រេចរាល់ភារកិច្ចរបស់ក្រសួង ស្ថាប័ន ព្រមទាំងចូលរួមគាំទ្រ និងអនុវត្តកម្មវិធីនយោបាយ គោលការណ៍ សេចក្តីសម្រេចនានារបស់គណបក្ស។

៣-ដឹកនាំ និងត្រួតពិនិត្យ អង្គការមូលដ្ឋានរបស់គណបក្ស ក្នុងការអនុវត្តការងារនយោបាយសតិអារម្មណ៍ ចាត់តាំង និងចលនាមហាជន។ ទន្ទឹមនេះ ត្រូវបង្កលក្ខណៈជួយឧបត្ថម្ភដល់អង្គការសង្គម និងក្រុមការងាររបស់គណបក្សដែលចាត់តាំងឡើងក្នុងក្រសួង ស្ថាប័ន ឲ្យធ្វើសកម្មភាពបានត្រឹមត្រូវតាមតួនាទីភារកិច្ចរបស់ខ្លួន និងមានប្រសិទ្ធភាព។

៤-លើកឡើងនូវគោលការណ៍ និងវិធានការដើម្បីជំរុញការងារគ្រប់គ្រង ពង្រឹងពង្រីកសមាជិកគណបក្ស សំដៅធានាបានទាំងបរិមាណ និងគុណភាព ។

ចំពោះសមាជិកគណបក្ស ជាមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័ន ដែលឈរជើងបំពេញភារកិច្ចការងារនៅមូលដ្ឋាន ត្រូវចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងមូលដ្ឋានរបស់គណបក្ស ចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៥-ត្រួតពិនិត្យសមាជិក និងអង្គការចាត់តាំងគណបក្ស ក្នុងការអនុវត្តលក្ខន្តិកៈគណបក្ស គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស និងត្រួតពិនិត្យហិរញ្ញវត្ថុរបស់គណបក្ស ។

៦-ចាត់តាំងផ្សព្វផ្សាយអំពីសភាពការណ៍រួម គោលការណ៍ និងសេចក្តីសម្រេចនានារបស់គណបក្សដល់សមាជិកគណបក្ស និងធ្វើរបាយការណ៍អំពីសភាពការណ៍ ការងារគណបក្ស និងលើកយោបល់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល តាមការកំណត់។

គ-អំពីសិទ្ធិ

គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន មានសិទ្ធិ:

១-ណែនាំ និងត្រួតពិនិត្យការអនុវត្តរាល់ភារកិច្ចការងាររបស់គណបក្ស ក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នរបស់ខ្លួន។

២-សម្រេចតែងតាំង ដំឡើងឋានៈ ប្រគល់ភារកិច្ច លើកសរសើរ និងដាក់វិន័យចំពោះមន្ត្រីគណបក្ស ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

៣-សម្រេចបង្កើត រំសាយ និងរៀបចំសមាសភាពដឹកនាំនៃគណៈកម្មាធិការសាខា សាខា អនុសាខា ក្រុមបក្ស(បើមាន) និងសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ។

៤-លើកសំណើសុំសេចក្តីសម្រេចពីគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល អំពីការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។

៥-លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ដើម្បីសុំសេចក្តីសម្រេចអំពីការងារមន្ត្រីគណបក្ស ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់កណ្តាល និងអំពីការងារគណបក្សដែលមានការលំបាកស្មុគស្មាញ និងសំណូមពររបស់សមាជិកគណបក្សដែលគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន មិនអាចដោះស្រាយបាន ។

៦-រួមយោបល់អំពីការងាររៀបចំមន្ត្រីគណបក្ស ចូលកាន់មុខនាទីក្នុងបណ្តាផ្នែក និងអង្គភាពចំណុះរបស់ក្រសួង ស្ថាប័ន ។

៧-រួមយោបល់អំពីការរៀបចំមន្ត្រីគណបក្សចូលកាន់មុខនាទីជាប្រធានមន្ទីរជំនាញនៃក្រសួង ស្ថាប័ន នៅថ្នាក់រាជធានី ខេត្ត ។ ក្នុងករណីមានយោបល់ខុសគ្នារវាងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវរាយការណ៍ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ពិនិត្យសម្រេច ។

## II.<u>**រចនាសម្ព័ន្ធ អង្គការចាត់តាំង**</u>

### ក-<u>អំពីរចនាសម្ព័ន្ធ</u>

រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវមានមន្ត្រីគណបក្សជាថ្នាក់ដឹកនាំសំខាន់ៗ វ័យចាស់ វ័យក្មេង នារី ដែលមានសមត្ថភាព មានសុខភាពល្អ មានបទពិសោធន៍ការងារគណបក្ស មានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈគោលជំហរនយោបាយរឹងមាំ មានគុណធម៌ សីលធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន មានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

ការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវបានកំណត់ដូចខាងក្រោមៈ

-គណៈកម្មាធិការគណបក្ស រួមមានសមាសភាពមន្ត្រីគណបក្សជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង ថ្នាក់នាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែល និងប្រធានគណៈកម្មាធិការសាខាគណបក្សមួយចំនួន ។

-គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស រួមមានសមាសភាពមន្ត្រីគណបក្សជារដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រីដែលទទួលបន្ទុកលើវិស័យការងារសំខាន់ៗ របស់គណបក្ស និងរបស់ក្រសួង ស្ថាប័ន ។

-គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដែលមានសមាជិកគណៈកម្មាធិការកណ្តាលចំនួន ០៣រូបចុះ ត្រូវរៀបចំបែងចែកភារកិច្ចជូនសមាជិកគណៈកម្មាធិការកណ្តាលទាំងអស់ជាប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស ។ ចំពោះគណៈកម្មាធិការគណបក្ស ដែលមានចំនួនសមាជិកគណៈកម្មាធិការកណ្តាលច្រើនជាង អាចរៀបចំសមាជិកគណៈកម្មាធិការកណ្តាលមួយចំនួនជាសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។

**ខ-អំពីបរិមាណ**

បរិមាណសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័នដែលរួមមាន ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិក ត្រូវបានកំណត់ដូចខាងក្រោមៈ

-សមាជិកគណៈកម្មាធិការគណបក្សមានចំនួន ៣៣រូបចុះ ចំពោះក្រសួង ស្ថាប័នដែលមានសាខាគណបក្ស ចំណុះចំនួន ១២ឡើងទៅ ។

-សមាជិកគណៈកម្មាធិការគណបក្សមានចំនួន ២៧រូបចុះ ចំពោះក្រសួង ស្ថាប័នដែលមានសាខាគណបក្ស ចំណុះចំនួន ១១ចុះ ។

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដែលរួមមានប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ ត្រូវមានចំនួនមិនលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សទាំងមូល ។ អនុប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវមានចំនួន ១ ទៅ ២ រូប។ ដោយឡែកចំពោះក្រសួង ស្ថាប័ន ដែលមានសាខាគណបក្សចំណុះចំនួន១២ ឡើងទៅ អាចរៀបចំឲ្យមានអនុប្រធាន ៣រូប ។

គ- គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវផ្អែកលើគោលការណ៍អំពីរចនាសម្ព័ន្ធ លក្ខណសម្បត្តិមន្ត្រី សមាសភាព និងបរិមាណដូចបានកំណត់ខាងលើនេះ និងត្រូវផ្អែកលើលក្ខណៈពិសេសនៃភារកិច្ចរបស់ក្រសួង ស្ថាប័ន និងសំណូមពរការងារ ដើម្បីលើកសំណើរៀបចំសមាសភាពគណៈកម្មាធិការគណបក្ស គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សឲ្យបានសមស្រប ដោយធានាបាននូវនិរន្តរភាពការងារគណបក្សនៅពេលមានការផ្លាស់ប្តូរអាណត្តិមន្ត្រី ។

គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវរៀបចំបែងចែកភារកិច្ចជូនសមាជិកម្នាក់ៗ ក្នុងគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ឲ្យទទួលបន្ទុកចង្កោមការងារ ឬផ្នែកការងារនីមួយៗរបស់គណបក្ស ជាអាទិ៍ការងារត្រួតពិនិត្យ ការងារចាត់តាំង ការងារឃោសនាអប់រំ ការងារហិរញ្ញវត្ថុ ការងារចលនាមហាជន ការងារសន្តិសុខ ការងាររដ្ឋបាល និងទទួលបន្ទុកដឹកនាំកសាងពង្រឹងតាមសាខាគណបក្ស និងផ្នែកចំណុះរបស់ក្រសួង ស្ថាប័ន ស្របតាមសំណូមពរ ភារកិច្ចជាក់ស្តែងរបស់ខ្លួន ។

## III.**របៀបរបបធ្វើការ**

### ក-គណៈកម្មាធិការគណបក្ស

គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដឹកនាំការងារគណបក្សថ្នាក់ខ្លួន ឆ្លងតាមរយៈសន្និបាត ឬប្រជុំពេញអង្គក្នុង១ខែម្តង ។ ការងារសំខាន់ៗ ដែលត្រូវដាក់ជូនគណៈកម្មាធិការគណបក្ស សម្រេចរួមមាន៖

១-សភាពការណ៍ ទិសដៅភារកិច្ចនយោបាយ និងវិធានការចាត់តាំងអនុវត្តសេចក្តីសម្រេចចិត្ត និងគោលការណ៍សំខាន់ៗរបស់គណៈកម្មាធិការកណ្តាល និងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតគណបក្សថ្នាក់ខ្លួន ។

២-របាយការណ៍បូកសរុបវាយតម្លៃសភាពការណ៍ការងារគណបក្ស និងទិសដៅភារកិច្ចផែនការប្រចាំឆមាស ប្រចាំឆ្នាំរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។

៣-គោលការណ៍ថ្មីសំខាន់ៗ អំពីការងាររបស់គណបក្ស។

៤-សំណើរៀបចំសមាសភាពគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។

៥-គោលការណ៍ និងសេចក្តីព្រាងខ្លឹមសារសម្រាប់បើកមហាសន្និបាតគណបក្សក្រសួង ស្ថាប័ន តាមការណែនាំរបស់គណៈកម្មាធិការកណ្តាល។

៦-បញ្ហាផ្សេងៗ ដែលភាគច្រើននៃសមាជិកគណៈអចិន្ត្រៃយ៍មិនទាន់មានការឯកភាព និងឃើញថាចាំបាច់ត្រូវលើកយកមកដាក់ជូនគណៈកម្មាធិការគណបក្សសម្រេច ។

### ខ-គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ទទួលខុសត្រូវដឹកនាំការងារគណបក្សក្រសួង ស្ថាប័ន ក្នុងចន្លោះពេលពីសន្និបាតពេញអង្គមួយទៅសន្និបាតពេញអង្គមួយទៀតរបស់គណៈកម្មាធិការគណបក្ស ។ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ក្នុងមួយខែត្រូវប្រជុំ ២ដង ក្នុងករណីចាំបាច់អាចប្រជុំវិសាមញ្ញ ។

ការងាររបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រួមមាន៖

១-ដឹកនាំ ណែនាំ ចាត់តាំងអនុវត្តសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន និងគោលការណ៍កំណត់ទាំងឡាយរបស់គណៈកម្មាធិការកណ្តាល ។

២-ដឹកនាំ ពង្រឹង អង្គការចាត់តាំងរបស់គណៈកម្មាធិការគណបក្ស គណៈកម្មាធិការសាខា និងសាខាគណបក្សចំណុះ និងណែនាំត្រួតពិនិត្យការអនុវត្តភារកិច្ចការងារគណបក្ស ការងារពង្រឹងមូលដ្ឋាន និងចលនាមហាជន ។

៣-សហការ និងជួយឧបត្ថម្ភដល់ក្រុមការងាររបស់គណបក្ស និងអង្គការសង្គម ដែលបានចាត់តាំងឡើង នៅក្នុងក្រសួង ស្ថាប័ន ដើម្បីបំផុសចលនាមហាជន ចូលរួមកសាងការពារសមិទ្ធផលសង្គមជាតិ និងគាំទ្រ កម្មវិធីនយោបាយរបស់គណបក្ស ។

៤-សម្រេចការងារមន្ត្រីដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ និងលើកសំណើរៀបចំមន្ត្រីគណបក្ស ក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ន ដែលស្ថិតក្នុងសមត្ថកិច្ចសម្រេចរបស់គណៈអចិន្ត្រៃយ៍គណៈ កម្មាធិការកណ្តាល ។

៥-ចាត់តាំងផ្សព្វផ្សាយសភាពការណ៍ ភារកិច្ចដល់គណៈកម្មាធិការគណបក្ស គណៈកម្មាធិការសាខា និងសាខាគណបក្សចំណុះ និងអនុវត្តរបបរាយការណ៍តាមការកំណត់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការ កណ្តាល ។

៦-កោះប្រជុំ និងត្រៀមរៀបចំខ្លឹមសារសន្និបាត ឬប្រជុំពេញអង្គគណៈកម្មាធិការគណបក្ស និងរាយការណ៍ជូនគណៈកម្មាធិការគណបក្ស អំពីសភាពការណ៍ការងារដែលគណៈអចិន្ត្រៃយ៍បានសម្រេច ។

គ-<u>ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស</u>

-ប្រធានគណៈកម្មាធិការគណបក្ស ជាប្រធានគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ទទួលខុសត្រូវដឹកនាំរួម តាមគោលការណ៍ ដែលបានសម្រេចដោយគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ។

-អនុប្រធានគណៈកម្មាធិការគណបក្ស ទទួលខុសត្រូវជួយប្រធាន ដឹកនាំការងារមួយចំនួនតាម ការប្រគល់ភារកិច្ចរបស់ប្រធាន និងគណៈអចិន្ត្រៃយ៍ និងជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន ។

-សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវផ្អែកលើសេចក្តី សម្រេចចិត្ត និងគោលការណ៍នានារបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ដើម្បីដឹកនាំ ណែនាំ និងចាត់តាំងអនុវត្តនៅតាមផ្នែកការងារ និងសាខាគណបក្សចំណុះដែលខ្លួនទទួលខុសត្រូវ។ ត្រូវកំណត់របប ប្រជុំជីវភាពគណបក្សឲ្យបានទៀងទាត់ ក្តាប់សភាពការណ៍ និងសំណូមពររបស់មន្ត្រីសមាជិកគណបក្ស និង មហាជន ដើម្បីលើកសំណើជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ចេញសេចក្តីសម្រេចចិត្ត គោលការណ៍ វិធានការដឹកនាំរួម ។

-ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដឹកនាំការងារគណបក្សតាមស្មារតីសម្រេចនៃសមូហភាពគណៈអចិន្ត្រៃយ៍ ឬគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។ នៅពេលពិភាក្សាការងារ ត្រូវគោរពមតិប្រជាធិបតេយ្យ ក្រោយពេលអនុម័ត ភាគតិចត្រូវគោរព ភាគច្រើន ហើយត្រូវអនុវត្តតាមគោលការណ៍ដែលសមូហភាពបានសម្រេច ។ ការអនុម័តរបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស កំណត់យកសម្លេងភាគច្រើនដាច់ខាត នៃសមូហភាពគណៈអចិន្ត្រៃយ៍ទាំងមូល ឬគណៈកម្មាធិការគណបក្សទាំងមូល លើកលែងតែការងារមួយចំនួនដែលមានកំណត់ដោយឡែកក្នុង លក្ខន្តិកៈគណបក្ស ។

សេចក្តីកំណត់លេខ ០១ សណ.គក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩១ និងសេចក្តីណែនាំបន្ថែមលេខ ១០៤ សណ.គក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ដែលមានខ្លឹមសារខុសពីសេចក្តីណែនាំនេះត្រូវទុកជានិរាករណ៍ ។

ខុទ្ទកាល័យ គណៈចាត់តាំងគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ។

ជ.គណៈអចិន្ត្រៃយ៍

ប្រធាន

ជា ស៊ីម

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្ដាល

លេខ : ០០៥/១៨ លគ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃពុធ ៧ រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ ២០១៨

**ជម្រាបជូន**

**- ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត**
**- ឯកឧត្តមប្រធានគណៈកម្មការគ្រប់គ្រងសមាជិកបក្សចំណុះថ្នាក់កណ្ដាល**

**យោង** : - ប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុងគណបក្ស
- សេចក្ដីណែនាំលេខ ០៨/១៥ សណ.គក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥

អនុវត្តតាមគោលការណ៍កំណត់ក្នុងប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុងគណបក្សដែលចែងថា "...សមាជិកគណៈកម្មាធិការកណ្ដាលធ្វើសកម្មភាពនៅទីណា ត្រូវរួមចំណែកទទួលខុសត្រូវក្នុងការដឹកនាំការងារគណបក្ស និងចូលរួមក្នុងការកសាងពង្រឹងគណបក្សនៅទីនោះ ។ ..."

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល** ណែនាំបន្ថែមដល់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគណៈកម្មការគ្រប់គ្រងសមាជិកបក្សចំណុះថ្នាក់កណ្ដាល ដូចខាងក្រោម :

១. ត្រូវពិនិត្យរៀបចំបំពេញបន្ថែមសមាជិកគណៈកម្មាធិការកណ្ដាលទាំងអស់ជាសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគណៈកម្មការគ្រប់គ្រងសមាជិកបក្សចំណុះថ្នាក់កណ្ដាល ។ ចំពោះគណៈកម្មាធិការគណបក្សដែលមានសមាជិកគណៈកម្មាធិការកណ្ដាលចំនួន ៣រូបចុះ ត្រូវរៀបចំបែងចែកភារកិច្ចជូនសមាជិកគណៈកម្មាធិការកណ្ដាលទាំងអស់ជាប្រធាន អនុប្រធាន និងសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ។

២. ត្រូវអញ្ជើញសមាជិកគណៈកម្មាធិការកណ្ដាលដែលជាអ្នកដឹកនាំនៃស្ថាប័ន អង្គភាពឈរជើងធ្វើសកម្មភាពពាក់ព័ន្ធនឹងមូលដ្ឋាន ចូលរួមរាល់កិច្ចប្រជុំពេញអង្គនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

ខ្លឹមសារដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវប្រធានចាត់ចែងអនុវត្តស្របតាមគោលការណ៍កំណត់របស់គណបក្ស ។

**ជ.គណៈអចិន្ត្រៃយ៍**
**អនុប្រធាន**

**សាយ ឈុំ**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល
លេខៈ០០៣/០៦២៤/សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម
ថ្ងៃ សុក្រ ១៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២៤

# សេចក្តីណែនាំ
# ស្តីពី
# រចនាសម្ព័ន្ធ សមាសភាព និងបរិមាណសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន

**<u>យោង</u>** : - សេចក្តីណែនាំលេខ ០៨/១៥ សណ.គក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥
- សេចក្តីណែនាំលេខ ០០២/២០ សណ.គក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២០
- សំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្សនាពេលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល នាថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០២៤

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល**ណែនាំអំពីការរៀបចំរចនាសម្ព័ន្ធ សមាសភាព និងបរិមាណសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដូចខាងក្រោម ៖

១. រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវរៀបចំតាមសេចក្តីណែនាំលេខ ០៨/១៥ សណ.គក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥ រួមមានមន្ត្រីគណបក្សជាថ្នាក់ដឹកនាំសំខាន់ៗ វ័យចាស់ វ័យក្មេង នារី ដែលមានសមត្ថភាព មានសុខភាពល្អ មានបទពិសោធន៍ការងារគណបក្ស មានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈគោលជំហរនយោបាយរឹងមាំ មានគុណធម៌សីលធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន មានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

២. សមាសភាពសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវរៀបចំតាមសេចក្តីណែនាំលេខ ០០២/២០ សណ.គក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២០ រួមមានមន្ត្រីគណបក្សក្នុងតំណែងជាប្រធាន អនុប្រធានស្ថាប័ន រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង និងថ្នាក់ប្រហាក់ប្រហែល ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះ និងមន្ត្រីដែលទទួលបន្ទុកលើវិស័យការងារសំខាន់ៗរបស់គណបក្ស ហើយជាមន្ត្រីដែលមានគ្រប់លក្ខណសម្បត្តិ ។

ដោយឡែកចំពោះគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដែលមានតែនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលចំណុះ (មិនមានអគ្គនាយកដ្ឋាន) រួមមានទាំងសមាសភាពមន្ត្រីថ្នាក់នាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលទីប្រឹក្សាក្រសួង ស្ថាប័ន ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន និងប្រធានគណៈកម្មាធិការសាខាគណបក្សចំណុះផ្ទាល់មួយចំនួន ។

ចំពោះសមាជិកគណៈកម្មាធិការកណ្ដាលត្រូវរៀបចំទាំងអស់ជាសមាជិកនៃគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដែលសាមីខ្លួនបំពេញភារកិច្ច ។

៣. សមាសភាពគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រួមមានមន្ត្រីគណបក្សជាប្រធានស្ថាប័ន រដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រីដែលទទួលបន្ទុកលើវិស័យការងារសំខាន់ៗរបស់គណបក្ស និងរបស់ក្រសួង ស្ថាប័ន ។

៤. បរិមាណសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវបានកែសម្រួល និងកំណត់ ៖

- មានចំនួន ៨៣ រូបចុះ ចំពោះក្រសួង ស្ថាប័នដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះចំនួន ៧ ឡើងទៅ
- មានចំនួន ៧១ រូបចុះ ចំពោះក្រសួង ស្ថាប័ន ដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះចំនួន ៦ ចុះ
- មានចំនួន ៥៩ រូបចុះ ចំពោះក្រសួង ស្ថាប័ន ដែលមានតែនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលចំណុះ (មិនមានអគ្គនាយកដ្ឋាន)

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សមានចំនួនមិនលើស ១ភាគ៣ នៃចំនួនសរុបសមាជិកគណៈកម្មាធិការគណបក្សនៃក្រសួង ស្ថាប័ន ។

៥. អនុប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវមានចំនួន ១ ទៅ ២ រូប ។

ដោយឡែកចំពោះក្រសួង ស្ថាប័ន ដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋាន និងគណៈកម្មាធិការសាខាគណបក្សចំណុះផ្ទាល់ចំនួន ១២ ឡើងទៅ អាចរៀបចំឲ្យមានអនុប្រធាន ៣ រូប ។ ក្រសួង ស្ថាប័ន ដែលមានគណៈកម្មាធិការគណបក្សមូលដ្ឋាន និងគណៈកម្មាធិការសាខាគណបក្សចំណុះផ្ទាល់ចំនួន ១៨ ឡើងទៅ អាចរៀបចំឲ្យមានអនុប្រធាន ៤ រូប ។

៦. សមាជិកគណៈកម្មាធិការកណ្តាលដែលបានទទួលអាណត្តិជាសមាជិកព្រឹទ្ធសភា ឬតំណាងរាស្ត្រ និងបានបញ្ចប់ភារកិច្ចការងារពីក្រសួង ស្ថាប័ន ត្រូវបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលឧទ្ទេសនាមឲ្យចូលរួមជីវភាពគណបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត នៃមណ្ឌលបោះឆ្នោតរបស់ខ្លួនរហូតដល់ចប់អាណត្តិ ។

សមាជិកគណៈកម្មាធិការកណ្តាលដែលត្រូវបានឈប់សម្រាកពីការងារ ត្រូវបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលឧទ្ទេសនាមជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដើម្បីរៀបចំឲ្យចូលរួមជីវភាពគណបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ឬគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ដែលសាមីខ្លួនរស់នៅ ។

៧. សេចក្តីណែនាំពីមុន ដែលមានខ្លឹមសារផ្ទុយពីសេចក្តីណែនាំនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ឧទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន និងស្ថាប័នគណបក្សដែលពាក់ព័ន្ធ ត្រូវប្រតិបត្តិតាមសេចក្តីណែនាំនេះ ។

**ជ.គណៈអចិន្ត្រៃយ៍**
**ប្រធាន**

**ហ៊ុន សែន**